ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី អន្តរាគមជួយពលការិនីខ្មែរ២នាក់

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរចំនួន**២នាក់** ដូចខាងក្រោម៖

**(១)** ពលការិនី **ស.យ** អាយុ៣៣ឆ្នាំ មកពីស្រុកសន្ទុក ខេត្តកំពង់ធំ បានទៅម៉ាឡេស៊ី ធ្វើការងារតាមផ្ទះ កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយធ្វើការលំបាក នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៧ នាងបានស្នើសុំស្ថានទូតជួយទាមទារប្រាក់ខែដែលនៅសល់ពីនិយោជក និងជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជករបស់ពលការិនី បានប្រគល់ប្រាក់ខែដែលនៅសល់ជូននាងចំនួន២៣០៨៩ រីងហ្គីត(ប្រហែល៥២៤៧ដុល្លារអាមេរិក) នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ។

**(២)** ពលការិនី **រ.ស.ម** អាយុ២៥ឆ្នាំ មកពីស្រុកសំបូរ ខេត្តក្រចេះ បានទៅម៉ាឡេស៊ីខុសច្បាប់ដោយខ្លួនឯង និងធ្វើការក្នុងភោជនីយដ្ឋានមួយកន្លែង កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៥។ ដោយចង់ត្រឡប់មកកម្ពុជាវិញ នាងបានស្នើសុំកិច្ចអន្តរាគមន៍ពីស្ថានទូត នៅថ្ងៃទី២១ ខែមេសា ឆ្នាំ ២០១៧ ហើយស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី។

ក្នុងអំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគដល់ពលការិនីទាំងពីរនាក់ ហើយពួកគេបានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**០៣** ខែ**ឧសភា ឆ្នាំ២០១៧** វេលាម៉ោង**០៧:៣៥**នាទីព្រឹក តាមជើងយន្តហោះ AK536 ។

គួរកត់សម្គាល់ថា ក្នុងត្រីមាសទី១ (ពីថ្ងៃទី០១ ខែមករា ដល់៣១ ខែមីនា) ឆ្នាំ២០១៧ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមជួយដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍ជូនពលរដ្ឋខ្មែរ ចំនួន**៦០នាក់** (ស្រី៥១នាក់ និងប្រុស០៩នាក់) ៕

ភ្នំពេញ, ថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ